អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## សវនាការក្នុងសំណុំរឿង ០០២/០២ ត្រូវបានផ្អាករហូតដល់ខែមករា ឆ្នាំ២០១៥

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានផ្អាកសវនាការជំនុំជម្រះក្តី ក្នុងសំណុំរឿង ០០២/០២ រហូតដល់ម៉ោង ៩ ព្រឹក ថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៥។ មូលហេតុនៃការផ្អាកសវនាការនេះ គឺដោយសារតែមេធាវីការពារក្តីលោក ខៀវ សំផន បន្តបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ នៅមុនកាលបរិច្ឆេទចុងក្រោយនៃការដាក់សារណាលើបណ្តឹងសាទុក្ខរបស់លោក ខៀវ សំផន ដែលត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១៤។

មុននឹងផ្អាកសវនាការ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា អង្គជំនុំជម្រះមានកាតព្វកិច្ចចម្បងក្នុងការចាប់ផ្តើមការជំនុំជម្រះក្តីក្នុងសំណុំរឿង ០០២/០២ ប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័ស ដើម្បីផលប្រយោជន៍យុត្តិធម៌។ អង្គជំនុំជម្រះបានធ្វើការកត់សម្គាល់ថា ការឃោគយល់ដែលអង្គជំនុំជម្រះបានធ្វើនានា រួមទាំងការកាត់បន្ថយចំនួនថ្ងៃសវនាការពី ៣ថ្ងៃ ក្នុង ១សប្តាហ៍ មកត្រឹម ២ថ្ងៃ ក្នុង ១សប្តាហ៍ គឺមិនបានទទួលលទ្ធផល ដែលធ្វើឲ្យមេធាវីការពារក្តីលោក ខៀវ សំផន មានវត្តមាននៅក្នុងសវនាការឡើយ។

ទោះបីជា មានការរកឃើញយ៉ាងច្បាស់កាលពីមុនថា ទង្វើរបស់ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន គឺជាការរារាំងកិច្ចដំណើរការនីតិវិធីក្តី អង្គជំនុំជម្រះបានថ្លែងថា អង្គជំនុំជម្រះមិនមានជម្រើសណាដែលសមស្របផ្សេងទៀត ក្រៅពីការផ្អាកសវនាការសំណុំរឿងនេះ រហូតដល់ខែមករា ឆ្នាំ២០១៥ ព្រោះថា ការប្រឹងប្រែងស្វែងរកមេធាវី ដើម្បីជំនួសក្រុមមេធាវីការពារក្តីលោក ខៀវ សំផន នៅពេលនេះ នឹងបណ្តាលឲ្យមានការពន្យាពេលសវនាការយ៉ាងច្រើន។ ហេតុផលគឺថា ពុំមានមេធាវីណាមួយដែលអាចមកជំនួសបានក្នុងរយៈពេលជូនដំណឹងដ៏ខ្លីបែបនេះ និងពេលវេលាដែលមេធាវីត្រូវការដើម្បីស្គាល់ច្បាស់នូវសំណុំរឿងដ៏ធំធេងនេះទេ។ កាលពីលើកមុន អង្គជំនុំជម្រះបានណែនាំទៅលោក ខៀវ សំផន ផងដែរថា សិទ្ធិទទួលបានមេធាវីការពារក្តីតាមការជ្រើសរើសរបស់ខ្លួន មិនមែនជាសិទ្ធិដាច់ខាតនោះទេ ហើយអង្គជំនុំជម្រះបាន

ប្រកាសថា អង្គជំនុំជម្រះនឹងបន្តស្វែងរកជម្រើសផ្សេងទៀត រួមទាំងលទ្ធភាពនៃការចាត់តាំងមេធាវីការពារក្តីបន្ថែម និងការបញ្ជូនរបាយការណ៍ស្តីពីកំហុសវិជ្ជាជីវៈរបស់មេធាវី ទៅអង្គភាពពាក់ព័ន្ធ អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


លោក **ឡាស អូលសិន**
មន្រ្តីផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥(0)១២ ៤៨៨ 0២៣
ទូរស័ព្ទ៖ +៨៥៥(0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

លោក **នេត្រ ភក្ត្រា**
មន្រ្តីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ៖ +៨៥៥(0)១២ ៤៨៨ ១៥៦
ទូរស័ព្ទ៖ +៨៥៥(0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh